Food and Agriculture Organization of the United Nations

This programme is co-funded by the European Union




# របាយការណ៍ស្ថិតិផលនេសាទសមុទ្រ
# ប្រចាំខែកញ្ញា ២០២៣

ចងក្រងដោយ៖ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ

*ការបោះពុម្ពផ្សាយនេះទទួលបានការគាំទ្រហិរញ្ញវត្ថុពីសហភាពអឺរ៉ុប។*
*ខ្លឹមសារនៃការបោះពុម្ពផ្សាយនេះ ជាការទទួលខុសត្រូវរបស់រដ្ឋបាលជលផល ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។*

# មាតិកា


**បញ្ជីតារាង** ............ ii

**បញ្ជីក្រាហ្វិក** ............ ii

**ឧបសម្ព័ន្ធ** ............ ii

*សេចក្តីថ្លែងអំណរគុណ* ............ iii

*ពាក្យបំព្រួញ* ............ iii

*សេចក្តីសង្ខេប* ............ iv

**១.សេចក្តីផ្តើម** ............ 1

**២. វិធីសាស្ត្រស្រាវជ្រាវ** ............ 1

**៣. លទ្ធផល** ............ 1

៣.១ ចំនួន ទូកនេសាទ/ការឡើងផលនេសាទអង្កេតនៅក្នុងខែកញ្ញា ............ 1

៣.២ សមត្ថភាពផលចាប់ក្នុង១ឯកតានៃឧបករណ៍នេសាទសំខាន់ៗ ............ 2

៣.៣ សមាមាត្រផលនេសាទដោយឧបករណ៍នេសាទសំខាន់ៗ ............ 4

៣.៤ ការរួមចំណែកផលនេសាទដោយក្រុមប្រភេទតាមទម្ងន់នៃការឡើងផលនេសាទ ............ 5

៣.៥ សមាសភាគផលនេសាទនៃប្រភេទតាមទម្ងន់ គ្រប់កន្លែងឡើងផលនេសាទ ............ 5

៣.៦ ការរួមចំណែកតាមក្រុមប្រភេទ តាមតម្លៃនៃផលនេសាទ ............ 6

៣.៧ សមាសភាគផលចាបតាមប្រភេទ តាមតម្លៃផលចាប់តាមកន្លែងឡើងផលនេសាទ ............ 7

៣.៨ ការប៉ាន់ប្រមាណផលនេសាទសរុប ............ 8

## បញ្ជីតារាង

តារាងទី១. ចំនួននៃការឡើងផលនេសាទ ដែលត្រូវបានកត់ត្រាតាមខេត្តនិងកន្លែងឡើងផលនេសាទ ...........2
តារាងទី២. CPUE (គីឡូក្រាម/ថ្ងៃ) សម្រាប់ឧបករណ៍នេសាទខ្នាតតូចនិងខ្នាតមធ្យម...............................3
តារាងទី៣. CPUE (គីឡូក្រាម/ថ្ងៃ) សម្រាប់ទូកអួនអូស តាមទំហំទូកនេសាទ .......................................3
តារាងទី៤. សមាមាត្រនៃផលចាប់តាមឧបករណ៍សំខាន់ៗ សម្រាប់ឧបករណ៍នេសាទខ្នាតតូចនិងខ្នាតមធ្យម..4
តារាងទី៥. សមាសភាគផលចាប់តាមប្រភេទ គ្រប់កន្លែងឡើងផលនេសាទទាំងអស់................................6
តារាងទី៦. តម្លៃសរុប (១០០០រៀល) រាយការណ៍តាមប្រភេទគ្រប់កន្លែងឡើងផលនេសាទទាំងអស់............7
តារាងទី៧. ផលចាប់ប៉ាន់ស្មានសរុបតាមប្រភេទឧបករណ៍- ទូកនេសាទ សំខាន់ៗ ...................................9

## បញ្ជីក្រាហ្វិក

ក្រាហ្វិកទី១.សមាសភាគផលនេសាទតាមក្រុមប្រភេទ គ្រប់កន្លែងឡើងផលនេសាទ................................5
ក្រាហ្វិកទី២. តម្លៃនៃផលនេសាទតាមក្រុមប្រភេទសំខាន់ៗ គ្រប់កន្លែងឡើងផលនេសាទ..........................7

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១. សមាសភាគផលនេសាទ តាមក្រុមប្រភេទគ្រប់កន្លែងឡើងផលនេសាទ តាមទម្ងន់និងតម្លៃ ...11
ឧបសម្ព័ន្ធទី២. ការរួមចំណែកផលចាប់តាមប្រភេទឧបករណ៍នេសាទនិងតាមខេត្ត ...................................12
ឧបសម្ព័ន្ធទី៣. សមត្ថភាពផលចាប់ក្នុង១ឯកតា CPUE តាមខេត្ត........................................................13
ឧបសម្ព័ន្ធទី៤. ផលនេសាទ តាមប្រភេទ តាមខេត្ត.........................................................................14

# សេចក្ដីថ្លែងអំណរគុណ

របាយការណ៍ស្ថិតិប្រចាំខែនេះ ត្រូវបានរៀបចំឡើងដោយមានជំនួយហិរញ្ញវត្ថុពីសហភាពអឺរ៉ុប ក្រោមកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាពនិងបរិយាប័ន្ន (CAPFISH)។ អ្នកចងក្រងរបាយការណ៍នេះសូមថ្លែងអំណរគុណដល់គម្រោងគាំទ្របច្ចេកទេសពីអង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO CAPFISH-Capture) ដែលបានគាំទ្រដល់ការបង្កើតវិធីសាស្ត្រនិងការបណ្ដុះបណ្ដាល ព្រមទាំងផ្ដល់ការណែនាំដល់ការប្រមូលនិងការវិភាគទិន្នន័យ។ អ្នកចងក្រងរបាយការណ៍ក៏សូមថ្លែងនូវអំណរគុណដល់ក្រុមមន្ត្រីប្រមូលទិន្នន័យនៃវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ (MaFReDI) សម្រាប់ការអនុវត្តការប្រមូលនិងបញ្ចូលទិន្នន័យយ៉ាងសកម្មរបស់ពួកគេ ព្រមទាំងការចូលរួមចំណែកបន្ថែមដល់ការបកស្រាយព័ត៌មាន។ អ្នកនិពន្ធសូមអរគុណយ៉ាងជ្រាលជ្រៅ ដល់មន្ត្រីមានសមត្ថកិច្ចមូលដ្ឋានគ្រប់លំដាប់ថ្នាក់ចំពោះការគាំទ្រនិងកិច្ចសហការនៅអំឡុងការចុះអនុវត្តការងារនៅទីវាល។

# ពាក្យបំព្រួញ

| | |
|---|---|
| CPUE | សមត្ថភាពផលចាប់ក្នុង១ឯកតា (Catch per Unit Effort) |
| EU | សហគមន៍អឺរ៉ុប |
| ε% | កំហុសស្តង់ដារប្រៀបធៀប (Relative Standard Error) |
| FAO | អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ |
| FCMAS | ការតាមដានវាយតម្លៃផលនេសាទសមុទ្រ |
| FiA | រដ្ឋបាលជលផល |
| FiAC | ខណ្ឌរដ្ឋបាលជលផល |
| KHR | រៀល |
| MaFReDI | វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ |
| MT | តោន |
| nei | គ្មានក្នុងក្រុមដទៃ (not elsewhere included) |
| SD | គម្លាតស្តង់ដារ (Standard Deviation) |
| US$ | ដុល្លារសហរដ្ឋអាមេរិក |

# សេចក្តីសង្ខេប

ទិន្នន័យអង្កេតផលនេសាទសម្រាប់ខែកញ្ញា ឆ្នាំ២០២៣ បង្ហាញថាការនេសាទអួនអូសមានផលចាប់ក្នុង១ឯកតាកម្លាំងនេសាទ (CPUE) ខ្ពស់ជាងគេបំផុត គឺ ២១៨,៨ គីឡូក្រាម/ថ្ងៃនេសាទ បន្ទាប់មកគឺការនេសាទដោយមងត្រីកាម៉ុងខ្នាតមធ្យម (១៧១,៨ គីឡូក្រាម/ថ្ងៃ) មងត្រីថ្មោង (៨៧,៧ គីឡូក្រាម/ថ្ងៃ) រនងខ្សែងចាប់មឹកពីងពាង (៧៧,៩ គីឡូក្រាម/ថ្ងៃ) មងបង្គា (៥៥,៥ គីឡូក្រាម/ថ្ងៃ) មងត្រី (២៨,៥ គីឡូក្រាម/ថ្ងៃ) និងលបក្តាម (១៥,៩ គីឡូក្រាម/ថ្ងៃ)។ មានភាពខុសគ្នាច្បាស់រវាង CPUE សម្រាប់ទូកអួនអូសខ្នាតតូចនិងខ្នាតធំ ដោយទូកអួនអូសមានប្រវែង ៦-១២ម៉ែត្រ មានផលចាប់ប្រចាំថ្ងៃជាមធ្យម ៨០,៨ គីឡូក្រាម និងទូកអួនអូសប្រវែង ១២-១៨ម៉ែត្រ មានផលចាប់ ៤១១,៤ គីឡូក្រាម/ថ្ងៃ។

មានការកត់ត្រាប្រភេទសរុបចំនួន ៣០ប្រភេទ ដោយក្នុងនោះ *Encrasicholina heteroloba* (ត្រីកាកឹម) រួមចំណែកច្រើនជាង ៣៤,២% នៃផលចាប់រាយការណ៍សរុបចំនួន **៩៩.៦៤៩** គីឡូក្រាម ក្នុងចំណោមការអង្កេតការឡើងផលនេសាទសរុប ២២៤។ ជាទូទៅ ត្រីរួមចំណែក ៨២% នៃចំនួនផលចាប់រាយការណ៍សរុប បន្ទាប់មកគឺក្រុមមឹក ៩,២% ក្រុមបង្គា ៥,៥% និងក្រុមក្តាម ១,៤%។ ចំណែកឯតម្លៃនៃផលចាប់វិញ ក្រុមមឹករួមចំណែក ៣៤,៣% ក្រុមត្រី ៣៤,៣% ក្រុមក្តាម ៩,៦% និងក្រុមបង្គា ១៩,៦%។ តម្លៃសរុបនៃផលចាប់ ដែលបានរាយការណ៍ គឺមាន **៣៧៩.៧៨៦.០០០** រៀល។

ផលចាប់ប៉ាន់ប្រមាណសរុបសម្រាប់ខែកញ្ញា ឆ្នាំ២០២៣ គឺមានចំនួន **៦៨២០** តោន ដែលភាគច្រើនបានមកពីការនេសាទដោយទូកអួនអូស (៦៣,៧%) និងការនេសាទខ្នាតតូចបានរួមចំណែកជាង ១៧,៥%។ តម្លៃនៃផលចាប់ប៉ាន់ស្មានសរុបដោយប្រើថ្លៃរាយការណ៍ជាមធ្យមគឺ **២៥.៩៩១.០២០.០០០** រៀល ឬ **៦.៣៣៩.២៧៣** ដុល្លារសហរដ្ឋអាមេរិក។

# ១.សេចក្តីផ្តើម

វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលផលសមុទ្រ (MaFReDI) ដោយមានជំនួយបច្ចេកទេសនៃកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាពនិងបរិយាប័ននៃអង្គការស្បៀងនិងកសិកម្ម នៃសហប្រជាប្រជាជាតិ (FAO CAPFISH) ក្រោមការគាំទ្រថវិការបស់សហភាពអឺរ៉ុប (EU) កំពុងអនុវត្តការអង្កេតផលចាប់ជលផលសមុទ្រតាមបែបវិទ្យាសាស្ត្រ នៅតាមកន្លែងឡើងផលនេសាទក្នុងខេត្តទាំងបួនតាមតំបន់ឆ្នេរ ចាប់តាំងពីខែមិថុនា ឆ្នាំ២០២១។ គោលបំណងនៃការអង្កេតនេះគឺដើម្បីធ្វើការប៉ាន់ប្រមាណ CPUE គិតជាគីឡូក្រាម/ថ្ងៃនេសាទ តាមឧបករណ៍នេសាទសំខាន់ៗ សមត្ថភាពនៃការធ្វើនេសាទប្រចាំខែ ផលនេសាទតាមប្រភេទនិងតម្លៃ ព្រមទាំងធ្វើការប៉ាន់ប្រមាណផលនេសាទសរុបពីទិន្នន័យប្រមូលបានពីកន្លែងឡើងផលនេសាទនៅខេត្តកំពត កែប កោះកុង និងព្រះសីហនុ។ របាយការណ៍នេះបង្ហាញអំពីលទ្ធផលចម្បងនៃការតាមដានផលនេសាទសមុទ្រនៅថ្នាក់ជាតិក្នុងប្រទេសកម្ពុជា សម្រាប់ខែកញ្ញា ឆ្នាំ២០២៣។

យោងតាមតម្រូវការអាទិភាពនិងសំណើរពីខណ្ឌរដ្ឋបាលជលផល ព័ត៌មានលម្អិតបន្ថែមអំពីលទ្ធផលតាមខេត្តនីមួយៗ មានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធ។

# ២. វិធីសាស្ត្រស្រាវជ្រាវ

វិធីសាស្ត្រស្រាវជ្រាវ ការរចនាសំណាក និងទម្រង់អង្កេតសម្រាប់ការអង្កេតតាមដានផលចាប់ជលផលសមុទ្រ (FCMAS) មានបញ្ចូលនៅក្នុងសៀវភៅណែនាំ ដែលអាចរកបានពីគេហទំព័រនៃរដ្ឋបាលជលផលតាមឯកសារយោងដូចខាងក្រោមៈ

រដ្ឋបាលជលផល (FiA) ឆ្នាំ២០២១. ឯកសារណែនាំការអង្កេតផលចាប់ជលផលសមុទ្រក្នុងប្រទេសកម្ពុជា ចងក្រងដោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រនៃរដ្ឋបាលជលផល រាជធានីភ្នំពេញ ប្រទេសកម្ពុជា ៣៨ទំព័រ។

# ៣. លទ្ធផល

### ៣.១ ចំនួន ទូកនេសាទ/ការឡើងផលនេសាទអង្កេតនៅក្នុងខែកញ្ញា

ការប្រមូលទិន្នន័យសម្រាប់ខែកញ្ញា ឆ្នាំ២០២៣ ធ្វើឡើងនៅទីតាំងឡើងផលនេសាទចំនួន៨ ដោយមានកន្លែងឡើងផលនេសាទចំនួន២ នៅតាមខេត្តតំបន់ឆ្នេរនីមួយៗ (តារាងទី១)។ សរុបរួម មានការឡើងផលនេសាទពីទូកនេសាទខ្នាតតូចចំនួន ៤៨ និងទូកនេសាទខ្នាតមធ្យមចំនួន ១៧៦ ត្រូវបានកត់ត្រា។ ទូកនេសាទខ្នាតមធ្យមរួមមានប្រវែង ១២ម-២៤ម រួមនឹងទូកនេសាទអួនអូសទាំងអស់ដោយមិនគិតពីទំហំ ព្រមទាំងទូកអូសគ្រែងឈាម។

តារាងទី១. ចំនួននៃការឡើងផលនេសាទ ដែលត្រូវបានកត់ត្រាតាមខេត្តនិងកន្លែងឡើងផលនេសាទ

| ខេត្ត | កន្លែងឡើងផលនេសាទ | ថ្នាក់ទូក | | សរុបរួម |
|---|---|---|---|---|
| | | ខ្នាតតូច | ថ្នាក់មធ្យម | |
| កំពត | កំពង់កណ្តាល | ៣ | ២៥ | ២៨ |
| កំពត | ត្រពាំងរពៅ | ១៨ | ១០ | ២៨ |
| កែប | អំពែង | ១១ | ១៧ | ២៨ |
| កែប | អូរក្រសារ | ៥ | ២៣ | ២៨ |
| កោះកុង | ឧកញ៉ា លីយ៉ុងផាត់ | ១ | ២៧ | ២៨ |
| កោះកុង | ថ្មស | ១០ | ១៨ | ២៨ |
| ព្រះសីហនុ | ស្ទឹងហាវ | | ២៨ | ២៨ |
| ព្រះសីហនុ | ទំនប់រលក | | ២៨ | ២៨ |
| **សរុបរួម** | | ៤៨ | ១៧៦ | ២២៤ |

ការអង្កេតត្រូវបានអនុវត្តនៅកន្លែងឡើងផលនេសាទគោលដៅទាំងអស់រយៈពេលបួនថ្ងៃជាប់គ្នា ដូចៗគ្នា ដោយធ្វើការកត់ត្រាផលនេសាទពីការឡើងផលនេសាទដោយចៃដន្យចំនួន៧ ក្នុងមួយថ្ងៃៗ តាមរយៈការសម្ភាសន៍ (ការស្ទង់មតិតាមបែបរំលឹកឡើងវិញ) និងកំណត់មានស្រាប់ដោយត្រាពាណិជ្ជករ/អ្នកនេសាទ។

## ៣.២ សមត្ថភាពផលចាប់ក្នុង១ឯកតានៃឧបករណ៍នេសាទសំខាន់ៗ

ដោយសារ FCMAS ប្រើសំណាកគំរូចៃដន្យនៃការឡើងផលនេសាទ ចំនួនកំណត់ត្រាអង្កេតសម្រាប់ឧបករណ៍នេសាទប្រែប្រួលរវាងខែផ្សេងៗគ្នា ប៉ុន្តែឆ្លុះបញ្ចាំងពីប្រតិបត្តការនិងភាពញឹកញាប់នៃឧបករណ៍ ដែលប្រើនៅតាមកន្លែងឡើងផលនេសាទ ដែលត្រូវបានគ្របដណ្តប់ដោយការស្ទង់មតិ។ តារាងទី២ បញ្ចូលរាល់ឧបករណ៍នេសាទណា ដែលត្រូវបានអង្កេតចាប់ពី ២ដងឡើងទៅ ព្រោះអាចឱ្យគេវាយតម្លៃភាពត្រឹមត្រូវនៃស្ថិតិ ដោយធ្វើការគណនាកំហុសស្តង់ដារប្រៀបធៀប (ε%) នៃ CPUE ជាមធ្យម។ ទូកអួនអូសមាន CPUE ខ្ពស់បំផុតគឺ ២១៨,៨ គីឡូក្រាម/ថ្ងៃនេសាទ បន្ទាប់មកគឺមងត្រីកាម៉ុង (១៧១,៨ គីឡូក្រាម/ថ្ងៃ) មងត្រីផ្ទោង (៨៧,៧ គីឡូក្រាម/ថ្ងៃ) រលងខ្សែចាប់មឹកពីងពាង (៧៧,៩ គីឡូក្រាម/ថ្ងៃ) មងបង្គា (៥៥,៥ គីឡូក្រាម/ ថ្ងៃ) និងមងត្រី (២៨,៥ គីឡូក្រាម/ថ្ងៃ)។ ឧបករណ៍នេសាទខ្នាតតូចដែលមានតម្លៃ CPUE ខ្ពស់ជាងគេគឺមងត្រីកាម៉ុង (៤១ គីឡូក្រាម/ថ្ងៃ) និងមងត្រី (៣១,៣ គីឡូក្រាម/ថ្ងៃ)។ CPUE សម្រាប់ឧបករណ៍នេសាទទាំងនេះ ប្រើដោយទូកនេសាទខ្នាតតូចនិងខ្នាតមធ្យម មានផលនេសាទប្រហាក់ប្រហែលគ្នា។

តារាងទី២. CPUE (គីឡូក្រាម/ថ្ងៃ) សម្រាប់ឧបករណ៍នេសាទខ្នាតតូចនិងខ្នាតមធ្យម

| **ខ្នាតមធ្យម** | CPUE | N | SD | ε% |
|---|---|---|---|---|
| ទូកអួនអូស | 218.8 | 99 | 283.3 | 13.0% |
| មងត្រីកាម៉ុង | 171.8 | 12 | 87.8 | 14.8% |
| មងត្រីផ្ទោង | 87.7 | 3 | 84.9 | **55.8%** |
| រនងខ្សែងចាប់មឹកពីងពាង | 77.9 | 11 | 76.5 | **29.6%** |
| មងបង្គា | 55.5 | 7 | 5.5 | 3.8% |
| មងត្រី | 28.5 | 2 | 26.2 | **64.9%** |
| លបក្ដាម | 15.9 | 11 | 4.6 | 8.7% |
| លបត្រី | 15.6 | 28 | 7.4 | 8.9% |
| លបត្រីម្រើមព្រះ | 13.5 | 2 | 3.5 | 18.5% |
| **ខ្នាតតូច** | **CPUE** | **N** | **SD** | **ε%** |
| មងត្រីក្បក | 41.0 | 2 | 8.5 | 14.6% |
| មងត្រី | 31.3 | 18 | 20.1 | 15.1% |
| លបត្រីម្រើមព្រះ | 15.9 | 13 | 8.3 | 14.5% |
| លបក្ដាម | 14.7 | 2 | 0.4 | 2.0% |
| មងក្ដាម | 8.3 | 10 | 4.4 | 16.8% |

តម្លៃកំហុសស្តង់ដារប្រៀបធៀប (ε%) បង្ហាញពីភាពជាក់លាក់នៃស្ថិតិ ឬគម្លាតរំពឹងទុកនៃ CPUE ជាមធ្យម ដែលប៉ាន់ស្មានជុំវិញតម្លៃពិតនៃ CPUE។ ប្រសិនបើតម្លៃ ε% ខ្ពស់ជាង ២៥% បង្ហាញថាតម្លៃមធ្យមប៉ាន់ស្មានមិនគួរជឿទុកចិត្ត និងមិនគួរប្រើ។ ដូចតារាងទី២ បង្ហាញមានឧបករណ៍នេសាទតិចតួចប៉ុណ្ណោះ ដែលមានការប្រែប្រួលខ្ពស់ទាក់ទងទៅនឹងការប៉ាន់ប្រមាណ CPUE បញ្ហានេះភាគច្រើនទំនងជាបណ្ដាលមកពីភាពខុសគ្នានៃចំនួននៃការប្រើឧបករណ៍នេសាទ។ ភាពជាក់លាក់នៃស្ថិតិគឺអាចទទួលយកបានសម្រាប់ឧបករណ៍នេសាទភាគច្រើន។

តារាងទី៣. CPUE (គីឡូក្រាម/ថ្ងៃ) សម្រាប់ទូកអួនអូស តាមទំហំនាវានេសាទ

| **ទូកអួនអូស** | CPUE | N | SD | ε% |
|---|---|---|---|---|
| ខ្នាតតូច ៦-១២ម | 80.8 | 59 | 120.3 | 19.4% |
| ខ្នាតមធ្យម ១២-១៨ម | 411.4 | 39 | 326.8 | 12.7% |

ឧបករណ៍នេសាទដំណើរការដោយទូកនេសាទខ្នាតតូចនិងមធ្យមមានភាពខុសគ្នាតិចតួច លើកលែងតែឧបករណ៍នេសាទសកម្ម ដូចជាទូកអួនអូស។ CPUE នៃទូកអួនអូសមានភាពខុសគ្នាខ្លាំងរវាងថ្នាក់ទំហំទូកនេសាទ (តារាងទី៣) ទូកអួនអូសខ្នាតមធ្យមប្រវែង ១២-១៨ម៉ែត្រ មាន CPUE ៤១១,៤ គីឡូក្រាម/ថ្ងៃ ដែលច្រើនជាង ៥ដងនៃ CPUE ទូកអួនអូសប្រវែង ៦-១២ ម៉ែត្រ នេសាទបាន ៨០,៨ គីឡូក្រាម/ថ្ងៃ។

## ៣.៣ សមាមាត្រផលនេសាទដោយឧបករណ៍នេសាទសំខាន់ៗ

ការនេសាទដោយទូកអួនអូសបានរួមចំណែកខ្ពស់បំផុតទៅនឹងផលចាប់រាយការណ៍សរុប ដែលមានចំនួន ៧៤,៤% នៃផលចាប់។ មងត្រីរួមចំណែកខ្ពស់បំផុតទៅនឹងផលចាប់សរុបសម្រាប់ទូកនេសាទខ្នាតតូច។ នេសាទខ្នាតមធ្យមរួមចំណែកលើសពី ៩៧% នៃផលចាប់ដែលបានកត់ត្រា ឧបករណ៍នេសាទខ្នាតមធ្យមផ្សេងទៀតក្រៅពីទូកអួនអូស រួមចំណែក ២៣,១% នៃផលចាប់ ដែលបានរាយការណ៍។ ការនេសាទខ្នាតតូចរួមចំណែកត្រឹមតែ ២,៥% នៃទិន្នផលនេសាទកត់ត្រាសរុប។

តារាងទី៤. សមាមាត្រនៃផល នេសាទដោយឧបករណ៍សំខាន់ៗ សម្រាប់ឧបករណ៍នេសាទខ្នាតតូចនិងខ្នាតមធ្យម

| ខ្នាតមធ្យម (៩៧,៥%) | ផលចាប់ (%) |
|---|---|
| អួនអូស | 74.4% |
| មងត្រីកាម៉ុង | 14.9% |
| រលងខ្សែចាប់មឹកពីងពាង | 3.4% |
| ឧបករណ៍មិនមានបញ្ជាក់ | 2.0% |
| មងត្រីឆ្មោង | 1.7% |
| មងក្តាម | 0.5% |
| មងត្រី | 0.4% |
| លបក្តាម | 0.2% |
| ឧបករណ៍ផ្សេងទៀត | 0.1% |

| ខ្នាតតូច (២,៥%) | ផលចាប់ (%) |
|---|---|
| មងត្រីកាម៉ុង | 1.2% |
| មងត្រី | 0.6% |
| រនងខ្សែចាប់មឹកពីងពាង | 0.3% |
| លបត្រីម្រើមព្រះ | 0.2% |
| ឧបករណ៍ផ្សេងទៀត | 0.2% |

| | សរុប | កំពត | កែប | កោះកុង | ព្រះសីហនុ |
|---|---|---|---|---|---|
| អួនអូស | 74,113 | 1.4% | 0.7% | 21.7% | 76.3% |
| ឧបករណ៍ខ្នាតមធ្យមផ្សេងទៀត | 23,057.1 | 24.3% | 2.0% | 33.3% | 40.3% |
| ឧបករណ៍ខ្នាតតូច | 2,478.9 | 75.3% | 7.9% | 16.9% | 0.0% |
| សរុប | 99,649 | 8.5% | 1.2% | 24.3% | 66.1% |

លើសពីនេះ បើពិនិត្យមើលផលនេសាទតាមខេត្តសម្រាប់ខែកញ្ញា ឆ្នាំ២០២៣ ផលចាប់បានពីការនេសាទដោយទូកអួនអូសភាគច្រើនត្រូវបានរាយការណ៍ពីខេត្តព្រះសីហនុ បន្ទាប់មកខេត្តកោះកុង ទោះក្នុងបរិមាណផលចាប់ខុសគ្នាខ្លាំងក្តី រីឯខេត្តកំពតនិងកែបបញ្ចូលគ្នា រួមចំណែកត្រឹមតែ ២,១% ប៉ុណ្ណោះ។ ផលនេសាទភាគច្រើននៃការនេសាទខ្នាតមធ្យមផ្សេងទៀតគឺមាននៅខេត្តព្រះសីហនុនិងកោះកុង ផលនេសាទខ្នាតតូចភាគច្រើនមានរាយការណ៍នៅក្នុងខេត្តកំពត (សូមមើលព័ត៌មានលម្អិតបន្ថែម ឧបសម្ព័ន្ធទី៣)។

### ៣.៤ ការរួមចំណែកផលនេសាទដោយក្រុមប្រភេទតាមទម្ងន់នៃការឡើងផលនេសាទ

ផលនេសាទរាយការណ៍សរុបសម្រាប់ក្រុមប្រភេទទាំងអស់គឺ **៩៩.៦៤៩,៥** គីឡូក្រាម ត្រីជាក្រុមប្រភេទគ្របដណ្តប់លើផលចាប់សរុប ដែលមានស្ទើរតែ ៨២% នៃទំងន់ផលចាប់សរុប បន្ទាប់មកក្រុមប្រភេទមឹកមាន ៩,២% ក្រុមបង្គា ៥,៥% ក្រុមក្តាម ១,៤% និងក្រុមមិនមានបញ្ជាក់ប្រភេទច្បាស់លាស់មាន ០,១៤% (សូមមើលឧបសម្ព័ន្ធ១)។ ក្រុមប្រភេទផ្សេងទៀត (ត្រីឆ្លាមនិងបបែល) រួមចំណែកត្រឹមតែ ០,០៥% ប៉ុណ្ណោះ។




ក្រាហ្វិកទី១.សមាសភាគផល នេសាទតាមក្រុមប្រភេទ ដោយដាក់បញ្ចូលការឡើងផលនេសាទទាំងអស់

### ៣.៥ សមាសភាគផលនេសាទនៃប្រភេទតាមទម្ងន់ គ្រប់កន្លែងឡើងផលនេសាទ

ផលនេសាទរាយការណ៍សរុបសម្រាប់ខែកញ្ញា គឺ **៩៩.៦៤៩** គីឡូក្រាម សមាមាត្រផលចាប់តាមប្រភេទមានបង្ហាញក្នុងតារាងទី៥។ ប្រភេទ ដែលសម្បូរជាងគេបំផុតគឺត្រីកាកឹម *(Encrasicholina heteroloba)* ដែលរួមចំណែក ៣៤,២% នៃចំនួនផលចាប់រាយការណ៍សរុប។ បន្ទាប់មកមានក្រុមប្រភេទមួយចំនួនទៀតដូចជា ត្រីជី (១៧%) ប្រភេទត្រីចំរុះ (១១,៥%) ត្រីត្រីកាម៉ុងខ្លួនខ្លី (៨,៣%) និងត្រីកាម៉ុងឬត្រីប្លាធូ (៤,៨%) និងក្រុមមឹកពីងពាង ៤,២% និងផលចាប់ផ្សេងទៀត ១,៧%។ ប្រភេទមានផលនេសាទខ្ពស់ជាងគេទាំង២០ រួមចំណែក ៩៨,២% នៃផលចាប់រាយការណ៍សរុប។

តារាងទី៥. សមាសភាគផលចាប់តាមប្រភេទគ្រប់កន្លែងឡើងផលនេសាទទាំងអស់

| ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះជាភាសាអង់គ្លេស | ឈ្មោះជាភាសាខ្មែរ | ផលចាប់ (គ.ក្រ) | ផលចាប់ (%) |
|---|---|---|---|---|
| *Encrasicholina heteroloba* | Shorthead anchovy | កាកឹម | 34,090.0 | 34.2% |
| | trash fish | ត្រីដី | 16,978.0 | 17.0% |
| | Other fish nei | ប្រភេទត្រីចំរុះ | 11,430.5 | 11.5% |
| *Rastrelliger brachysoma* | Short mackerel | ត្រីផ្លាធូ ឬត្រីកាម៉ុងខ្លួនខ្លី | 8,237.5 | 8.3% |
| *Decapterus macrosoma* | Shortfin scad | ត្រីកាម៉ុងឬត្រីប្លាធូ | 4,754.0 | 4.8% |
| | Octopus | មឹកពីងពាង | 4,159.0 | 4.2% |
| | Squids nei | មឹក | 2,374.5 | 2.4% |
| *Penaeus sp.* | Prawns nei | បង្គា | 1,978.0 | 2.0% |
| | Needlefish nei | ត្រីផ្ទោង | 1,670.0 | 1.7% |
| | Other catch nei | ផ្សេងៗ | 1,656.5 | 1.7% |
| | Octopus | ពពួកមឹកពីងពាង | 1,616.0 | 1.6% |
| *scomberoides tala* | Barred queenfish | ត្រីកាឡាំង | 1,500.0 | 1.5% |
| *Portunus pelagicus* | Swimming crab | ក្តាមសេះ | 1,261.9 | 1.3% |
| | Small mixed shrimp nei | គី | 1,221.0 | 1.2% |
| *Metapenaeus spp.* | | បង្គាឱខាក់ | 1,166.0 | 1.2% |
| *Rastrelliger kanagurta* | Indian mackerel | ត្រីកាម៉ុងខ្លួនវែង | 855.0 | 0.9% |
| | Shrimps nei | ពពួកបង្គាគ្រប់ប្រភេទទាំងអស់ | 807.0 | 0.8% |
| *Scomberoides commersonianus* | Talang queenfish | ត្រីកាឡាំង | 800.0 | 0.8% |
| *Anodontostoma chacunda* | Chacunda gizzard shad | ត្រីកាម៉យ | 555.0 | 0.6% |
| *Suborder Sepiina* | Cuttlefish | មឹកស្នូក | 538.0 | 0.5% |
| | Other species | ប្រភេទផ្សេងទៀត | 1,231.1 | 1.2% |
| **សរុបរួម** | | | **99,649.0** | |

## ៣.៦ ការរួមចំណែកតាមក្រុមប្រភេទ តាមតម្លៃនៃផលនេសាទ

តម្លៃរាយការណ៍សរុបសម្រាប់ខែកញ្ញា មានចំនួន **៣៧៩.៧៨៦.១៨០** រៀល ក្នុងនោះ ត្រីរួមចំណែក ៣៤,៣% ក្រុមបង្គា ១៩,៦% ក្រុមមឹក ៣៤,៣% និងក្រុមក្តាម ៩,៦%។ ក្រុមដែលមិនបានបញ្ជាក់ប្រភេទរួមចំណែក ១,៨% ខណៈដែលក្រុមឆ្លាម បបែល និងសប្បីសត្វ ក្តាម បង្គា រួមចំណែក ០,១១% នៃតម្លៃសរុប (ព័ត៌មានលម្អិតបន្ថែមមានបញ្ចូលក្នុងឧបសម្ព័ន្ធទី២)។




ក្រាហ្វិកទី២. តម្លៃនៃផលនេសាទតាមក្រុមប្រភេទសំខាន់ៗ គ្រប់កន្លែងឡើងផលនេសាទទាំងអស់

### ៣.៧ សមាសភាគផលចាបតាមប្រភេទ តាមតម្លៃផលចាប់តាមកន្លែងឡើងផលនេសាទ

តម្លៃរាយការណ៍សរុបគ្រប់ប្រភេទទាំងអស់សម្រាប់ខែកញ្ញាគឺ **៣៧៩.៧៨៦.០០០** រៀល តម្លៃនិងថ្លៃតាមប្រភេទមានតម្លៃខ្ពស់ជាងគេទាំង ២០ប្រភេទ មានបង្ហាញក្នុងតារាងទី៦។ ប្រភេទ (ក្រុម) ដែលមានតម្លៃរាយការណ៍ខ្ពស់បំផុតគឺក្រុមមឹកពីងពាង (១៩,៣%) បន្ទាប់មកគឺក្រុមបង្គា ( ១០%) និងក្រុមក្តាមសេះ (៩,៣%)។ ត្រីកាម៉ុងខ្លួនខ្លី (៧,៨%) បង្គាឪខាក់ *Metapenaeus* (៦,២%) ត្រីចំរុះ (៦,៤%) និងបង្គា (៦,២%) ក៏ជាក្រុមប្រភេទសំខាន់ផងដែរ។ ត្រីកាគីម ដែលជាត្រីមានតម្លៃទាប (៤,៦%) មិនអាចរួមចំណែកច្រើនដល់តម្លៃផលចាប់សរុប។ ក្រុមប្រភេទ ដែលមានតម្លៃខ្ពស់ គឺក្រុមបង្គា ដែលរួមបញ្ចូលទាំងប្រភេទបង្គាមិនបានញែកប្រភេទ ដែលមិនបានកត់ត្រាប្រភេទ។ ក្រុមប្រភេទផ្សេងទៀត ផ្សេងពីក្រុមប្រភេទនេសាទបានច្រើនជាងគេទាំង ២០ប្រភេទ រួមចំណែក ៣,១% នៃតម្លៃរាយការណ៍សរុប។

តារាងទី៦. តម្លៃសរុប (១០០០រៀល) តាមប្រភេទនៅគ្រប់កន្លែងឡើងផលនេសាទទាំងអស់

| ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះទូទៅ | ឈ្មោះភាសាខ្មែរ | តម្លៃ (១០០០ រៀល) | តម្លៃ (%) | ថ្លៃ (រៀល/គ.ក្រ) |
|---|---|---|---|---|---|
| | Octopus | មឹកពីងពាង | 73,474 | 19.3% | 12,725 |
| | Squids nei | បង្គា | 37,923 | 10.0% | 18,100 |
| *Portunus pelagicus* | Swimming crab | ក្តាមសេះ | 35,347 | 9.3% | 25,350 |
| *Rastrelliger brachysoma* | Short mackerel | ត្រីកាម៉ុងខ្លួនខ្លី | 29,512 | 7.8% | 4,100 |
| *Metapenaeus spp.* | | បង្គាឪខាក់ | 28,528 | 7.5% | 24,850 |

| | | | | | |
|---|---|---|---|---|---|
| | Other fish nei | ត្រីចំរុះ | 24,440 | 6.4% | 2,600 |
| *Penaeus sp.* | Prawns nei | បង្គា | 23,728 | 6.2% | 17,450 |
| *Decapterus macrosoma* | Shortfin scad | ត្រីកាម៉ុង | 19,870 | 5.2% | 4,825 |
| *Encrasicholina heteroloba* | Shorthead anchovy | ត្រីកាកឹម | 17,587 | 4.6% | 525 |
| | Cephalopods (squids/cuttlefish) | ពពួកមឹកស្នូក និងមឹកបំពង់ | 9,862 | 2.6% | 16,000 |
| | Shrimps (unsorted) | ពពួកបង្គាទាំងអស់ | 9,550 | 2.5% | 12,775 |
| | trash fish | ត្រីជី | 9,258 | 2.4% | 700 |
| *scomberoides tala* | Barred queenfish | ត្រីកាឡាំង | 9,000 | 2.4% | 6,000 |
| *Suborder Sepiina* | Cuttlefish | មឹកស្នូក | 8,927 | 2.4% | 16,375 |
| | Needlefish nei | ត្រីផ្ទោង | 8,139 | 2.1% | 6,925 |
| | Other catch nei | ផ្សេងៗ | 6,698 | 1.8% | 15,050 |
| | Small mixed shrimp nei | គី | 4,884 | 1.3% | 4,000 |
| *Rastrelliger kanagurta* | Indian mackerel | ត្រីកាម៉ុងខ្លួនវែង | 4,240 | 1.1% | 4,400 |
| *Scomberoides commersonianus* | Talang queenfish | ត្រីកាឡាំង | 3,600 | 0.9% | 4,500 |
| | Shrimps nei | បង្គា | 3,260 | 0.9% | 80,800 |
| | Other species | ប្រភេទផ្សេងទៀត | 11,961 | 3.1% | |
| **សរុបរួម** | | | **379,786** | | |

សមាមាត្រដ៏ខ្ពស់នៃត្រីកាកឹមនិងត្រីជី ជាប្រភេទមានតម្លៃទាប ធ្វើអោយថ្លៃជាមធ្យមសម្រាប់ខែកញ្ញា គឺ ៣៨១១ រៀល/គីឡូក្រាម។

## ៣.៨ ការប៉ាន់ប្រមាណផលនេសាទសរុប

ការប៉ានប្រមាណផលចាប់សរុបត្រូវបានគណនាដាច់ពីគ្នាសម្រាប់ថ្នាក់ឧបករណ៍នេសាទ ដើម្បីកាត់បន្ថយបម្រែបម្រួលតម្លៃ CPUE។ យោងលើសារៈសំខាន់នៃនេសាទដោយទូកអួនអូសនិងបម្រែបម្រួលខ្ពស់នៃ CPUE ដែលទាក់ទងយ៉ាងជិតស្និទទៅនឹងប្រវែងនិងកម្លាំងម៉ាស៊ីនទូកនេសាទ ឧបករណ៍អួនអូសត្រូវបានបែងចែកតាមថ្នាក់ទំហំមូលដ្ឋានចំនួន ៣កម្រិត[1] បន្ថែមលើថ្នាក់ទូកនេសាទស្តង់ដាររបស់រដ្ឋបាលជលផល។ ទិន្នផលតាមទូកនេសាទប្រចាំខែគឺផ្អែកលើការប៉ាន់ប្រមាណ CPUE ឯករាជ្យ (ផលនេសាទមធ្យមប្រចាំថ្ងៃ) និងចំនួនថ្ងៃនេសាទប្រចាំខែ រីឯការបូក

[1] ទិន្នន័យឆ្នាំ២០២៣ មិនមានការកត់ត្រាឧបករណទូកអួនអូសតាមប្រភេទ

សរុបប្រើចំនួនទូកនេសាទតាមប្រភេទទូកនេសាទនីមួយៗ ផ្អែកលើទិន្នន័យជំរឿនទូកនេសាទឆ្នាំ២០១៨ ដោយធ្វើការសន្មត់ថាមានទូកនេសាទ ៨៥% ជាទូកនេសាទសកម្ម[2]។

ផលនេសាទ សរុបគណនាសម្រាប់ខែកញ្ញា ឆ្នាំ២០២៣ គឺ **៦៨២០** តោន។ យោងតាមផលចាប់ ដែលបានរាយការណ៍ ការនេសាទដោយអួនអូសមានការរួមចំណែកច្រើនជាងគេបំផុតដល់ផលនេសាទប៉ាន់ស្មានសរុបគឺចំនួន ៦៣,៧% ជាមួយនឹងទូកនេសាទខ្នាតតូចបានរួមចំណែកច្រើនជាង ១៥%។ ដោយសារតែចំនួនសង្កេតមិនគ្រប់គ្រាន់សម្រាប់ប្រភេទនាវា-ឧបករណ៍មួយចំនួនតាមខែខ្លះ ការគណនាផលនេសាទ សរុបប្រចាំខែក្នុងតារាងទី៧ ប្រើប្រាស់តម្លៃមធ្យមប្រចាំឆ្នាំសម្រាប់ CPUE និង សមត្ថភាពនេសាទ (Effort) សម្រាប់នាវានេសាទខ្នាតតូច < ៦ម៉ែត្រ ទូកអួនអូសប្រវែង ១៨-២៤ម៉ែត្រ និងនាវានេសាទខ្នាតធំ >២៤ម៉ែត្រ។ មានការអង្កេតការឡើងផលនេសាទតាមថ្នាក់ទូក-ឧបករណ៍ទាំងនេះតិចតួចប៉ុណ្ណោះត្រូវបានកត់ត្រា ពេញមួយឆ្នាំកន្លងទៅ ដូចនេះតម្លៃ ε% តំណាងឱ្យតម្លៃប្រចាំឆ្នាំ។

តារាងទី៧. ផលចាប់ប៉ាន់ស្មានសរុបតាមប្រភេទទូក ឧបករណ៍សំខាន់ៗ

| Vessel-gear category | ចំនួនអង្កេត | CPUE | ε% | សមត្ថភាពនេសាទ (Effort) | ទិន្នផលតាមនាវាប្រចាំខែ (គ.ក្រ) | ទូកនេសាទសកម្ម (៨៥%) | ទិន្នផលសរុបប្រចាំខែ (តោន) | %សរុប |
|---|---|---|---|---|---|---|---|---|
| ខ្នាតតូច <៦ម | 0 | 5.5 | (7.0%) | 5.0 | 27.5 | 775.2 | 21.3 | 0.3% |
| ខ្នាតតូច ៦-<១២ម | 48 | 30.0 | 23.2% | 13.2 | 395.5 | 2658 | 1,051.1 | 15.4% |
| អួនអូស ៦-<១២ម | 59 | 80.8 | 19.4% | 19.0 | 1,535.7 | 952 | 1,462.0 | 21.4% |
| អួនអូស ១២-១៨ម | 39 | 411.4 | 12.7% | 19.6 | 8,047.8 | 339.15 | 2,729.4 | 40.0% |
| អួនអូស ១៨-<២៤ម | 0 | 220.8 | **(88.7%)** | 16.0 | 3,533.3 | 42.5 | 150.2 | 2.2% |
| ឧបករណ៍ផ្សេងទៀត ១២-១៨ម | 66 | 48.9 | 15.5% | 14.1 | 690.3 | 1588.7 | 1,096.7 | 16.1% |
| ឧបករណ៍ផ្សេងទៀត ១៨-<២៤ម | 11 | 112.3 | **31.0%** | 15.8 | 1,776.7 | 55.25 | 98.2 | 1.4% |
| ខ្នាតធំ លើស ២៤ម | 1 | 1,340.7 | **(63.8%)** | 17.5 | 23,462.5 | 9 | 211.2 | 3.1% |
| **ផលចាប់ប៉ាន់ប្រមាណសរុបសម្រាប់ខែកញ្ញា** | | | | | | | **6,820.0** | |

[2] ផ្អែកលើព័ត៌មានផ្តល់ដោយមន្ត្រីខណ្ឌរដ្ឋបាលជលផល

តម្លៃ ៩%, តាមប្រភេទ ទូកនេសាទ-ឧបករណ៍ភាគច្រើន អាចទទួលយកបាន ក៏ប៉ុន្តែពេលធ្វើការប៉ាន់ប្រមាណប្រចាំឆ្នាំលើទូកនេសាទដែលមានទំហំវែងជាង ១៨ម៉ែត្រ ជាលទ្ធផលមិនមានភាពជាក់លាក់នៃស្ថិតិគ្រប់គ្រាន់។ ទោះជាយ៉ាងនេះក្តី ដោយសារថ្នាក់ទូកនេសាទ-ឧបករណ៍ទាំងនេះបានរួមចំណែកតិចជាង ៧% នៃផលចាប់ប៉ាន់ស្មានសរុប ធ្វើអោយមានការជឿទុកចិត្តថាផលនេសាទប៉ានស្មានសរុបចង្អុលបង្ហាញទៅនឹងតម្លៃជាក់ស្តែង។

ដោយប្រើតម្លៃរាយការណ៍មធ្យម តម្លៃសរុបនៃផលចាប់ប៉ាន់ប្រមាណមានចំនួន ២៨.៣០៣.១៩៩.០០០រៀល ឬ ៦.៩៦២.៥៨៦ ដុល្លារសហរដ្ឋអាមេរិក។

ថ្ងៃច័ន្ទ ១៥កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០២៤
ហត្ថលេខា

លោក ជា ថារិទ្ធ

បានឃើញ
ថ្ងៃអង្គារ ១រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ សីហា ឆ្នាំ២០២៤
ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល និងជាប្រធានគម្រោង CAPFISH-Capture

ពុំ សុធា

ឧបសម្ព័ន្ធទី១. សមាសភាគផលនេសាទ តាមក្រុមប្រភេទគ្រប់ការឡើងផលនេសាទ តាមទម្ងន់និងតម្លៃ

| ក្រុមប្រភេទ | ទម្ងន់សរុប (គ.ក្រ) | ទម្ងន់សរុប% (គ.ក្រ) |
|---|---|---|
| ត្រី | 8,1757 | 82.04% |
| មឹក | 9,197.5 | 9.23% |
| បង្គា | 5,454.1 | 5.47% |
| ក្រុមប្រភេទផ្សេងទៀត | 1,656.5 | 1.66% |
| ក្តាម | 1,443.9 | 1.45% |
| សប្បីសត្វ (មឹក បង្គា) | 89.5 | 0.09% |
| បបែល | 31.5 | 0.03% |
| ឆ្លាម | 19 | 0.02% |
| **សរុបរួម** | **99,649** | |

| ក្រុមប្រភេទ | តម្លៃសរុប (១០០០រៀល) | តម្លៃសរុប (%) |
|---|---|---|
| ត្រី | 130,251 | 34.30% |
| មឹក | 130,186 | 34.28% |
| បង្គា | 74,514 | 19.62% |
| ក្តាម | 36,387 | 9.58% |
| ផ្សេងទៀត | 6,698 | 1.76% |
| សប្បីសត្វ (មឹក បង្គា) | 1,323 | 0.35% |
| បបែល | 318 | 0.08% |
| ឆ្លាម | 117 | 0.03% |
| **សរុបរួម** | **379,786** | |
| | | |
| ថ្លៃមធ្យម | ៣៨១១រៀល/គ.ក្រ | |

ឧបសម្ព័ន្ធទី២. ការរួមចំណែកផលនេសាទតាមប្រភេទឧបករណ៍នេសាទនិងតាមខេត្ត

| ប្រភេទឧបករណ៍ | កោះកុង | ព្រះសីហនុ | កំពត | កែប | សរុបរួម (គ.ក្រ) |
|---|---|---|---|---|---|
| អួនអូស | 21.7% | 76.3% | 1.4% | 0.7% | 74,113.0 |
| មងត្រីកាម៉ុង | 28.5% | 51.0% | 20.5% | - | 16,075.0 |
| រនងខ្សែងចាប់មឹកពីងពាង | 91.8% | 8.2% | - | - | 3,640.0 |
| ផ្សេងទៀត | - | - | 100.0% | - | 2,000.0 |
| មងត្រីផ្ទោង | - | 21.2% | 78.8% | - | 1,650.0 |
| មងត្រី | 2.4% | - | 96.9% | - | 621.0 |
| មងក្តាម | 11.8% | 8.2% | - | 80.0% | 609.0 |
| មងបង្គា | 1.3% | 98.7% | - | - | 393.7 |
| លបត្រីម្រើមព្រះ | 39.8% | - | - | 60.2% | 233.5 |
| លបក្តាម | 3.0% | - | 81.9% | 15.1% | 231.8 |
| មងត្រីក្បក | - | - | 100.0% | - | 82.0 |
| **សរុបរួម** | **24.3%** | **66.1%** | **8.5%** | **1.2%** | **99,649.0** |

ឧបសម្ព័ន្ធទី៣. សមត្ថភាពផលចាប់ក្នុង១ឯកតា (CPUE) តាមខេត្ត

| ខេត្ត | ថ្នាក់នាវានេសាទ | ប្រភេទឧបករណ៍ | មធ្យម CPUE | N | SD | ε% |
|---|---|---|---|---|---|---|
| កំពត | ខ្នាតមធ្យម | លបក្តាម | 17.8 | 9 | 1.4 | 2.6% |
| | | មងត្រីកាម៉ុង | 105.0 | 2 | 7.1 | 4.8% |
| | | អួនអូស | 48.9 | 21 | 23.7 | 10.6% |
| | ខ្នាតតូច | លបក្តាម | 14.7 | 2 | 0.4 | 2.0% |
| | | មងត្រី | 34.7 | 16 | 18.8 | 13.5% |
| | | មងត្រីក្បក | 41.0 | 2 | 8.5 | 14.6% |
| | | | | | | |
| កែប | ខ្នាតមធ្យម | មងក្តាម | 17.8 | 22 | 6.6 | 8.0% |
| | | អួនអូស | 31.1 | 16 | 4.6 | 3.7% |
| | ខ្នាតតូច | លបត្រីម្រើមព្រះ | 13.0 | 10 | 6.1 | 14.9% |
| | | មងក្តាម | 12.2 | 5 | 2.3 | 8.4% |
| | | | | | | |
| កោះកុង | ខ្នាតមធ្យម | មងក្តាម | 6.7 | 5 | 3.0 | 20.0% |
| | | មងត្រីកាម៉ុង | 140.7 | 6 | 64.3 | 18.7% |
| | | រនងខ្សែចាប់មឹកពីងពាង | 85.9 | 9 | 83.0 | **32.2%** |
| | | អួនអូស | 197.9 | 22 | 278.6 | **30.0%** |
| | ខ្នាតតូច | លបត្រីម្រើមព្រះ | 25.7 | 3 | 7.6 | 17.0% |
| | | មងក្តាម | 4.5 | 5 | 1.2 | 11.8% |
| | | | | | | |
| ព្រះសីហនុ | ខ្នាតមធ្យម | មងត្រីផ្ទោង | 38.8 | 2 | 1.8 | 3.2% |
| | | មងត្រីកាម៉ុង | 251.8 | 4 | 89.0 | 17.7% |
| | | រនងខ្សែចាប់មឹកពីងពាង | 41.7 | 2 | 11.8 | 20.0% |
| | | មងបង្គា | 55.5 | 7 | 5.5 | 3.8% |
| | | អួនអូស | 394.6 | 40 | 312.5 | 12.5% |

## ឧបសម្ព័ន្ធទី៤. ផលនេសាទ តាមប្រភេទ តាមខេត្ត

| ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះភាសាអង់គ្លេស | ឈ្មោះភាសាខ្មែរ | កោះកុង | ព្រះសីហនុ | កំពត | កែប | ផលចាប់ (គ.ក្រ) | ផលចាប់ (%) |
|---|---|---|---|---|---|---|---|---|
| *Encrasicholina heteroloba* | Shorthead anchovy | កាកីម | - | 100.0% | - | - | 34,090.0 | 34.2% |
| | trash fish | ត្រីជី | 29.9% | 69.3% | - | 0.8% | 16,978.0 | 17.0% |
| | Other fish nei | ប្រភេទត្រីចំរុះ | 62.2% | 33.1% | 4.0% | 0.7% | 11,430.5 | 11.5% |
| *Rastrelliger brachysoma* | Short mackerel | ត្រីផ្លាធូ ឬត្រីកាម៉ុងខ្លួនខ្លី | 45.1% | 54.6% | 0.2% | - | 8,237.5 | 8.3% |
| *Decapterus macrosoma* | Shortfin scad | ត្រីកាម៉ុងឬត្រីប្លាធូ | - | 71.6% | 28.4% | - | 4,754.0 | 4.8% |
| | Octopus | មឹកពីងពាង | 76.1% | 21.7% | 1.5% | 0.7% | 4,159.0 | 4.2% |
| | Squids nei | មឹក | 74.8% | 22.6% | 2.6% | - | 2,374.5 | 2.4% |
| *Penaeus sp.* | Prawns nei | បង្គា | 20.4% | 69.5% | 0.4% | 9.7% | 1,978.0 | 2.0% |
| | Needlefish nei | ត្រីផ្ទោង | - | 21.0% | 78.0% | 1.0% | 1,670.0 | 1.7% |
| | Other catch nei | ផ្សេងៗ | - | - | 99.9% | 0.1% | 1,656.5 | 1.7% |
| | | ពពួកមឹកពីងពាង | - | 100.0% | - | - | 1,616.0 | 1.6% |
| *scomberoides tala* | Barred queenfish | ត្រីកាឡាំង | - | - | 100.0% | - | 1,500.0 | 1.5% |
| *Portunus pelagicus* | Swimming crab | ក្តាមសេះ | 8.8% | 35.3% | 20.3% | 35.6% | 1,261.9 | 1.3% |
| | Small mixed shrimp nei | គ្ងី | - | 100.0% | - | - | 1,221.0 | 1.2% |
| *Metapenaeus spp.* | | បង្គាឱខាក់ | 18.8% | 81.2% | - | - | 1,166.0 | 1.2% |
| *Rastrelliger kanagurta* | Indian mackerel | ត្រីកាម៉ុងខ្លួនវែង | 6.4% | - | 93.6% | - | 855.0 | 0.9% |
| | Shrimps (unsorted) | ពពួកបង្គាគ្រប់ប្រភេទទាំងអស់ | 85.1% | 14.9% | - | - | 807.0 | 0.8% |
| *Scomberoides commersonianus* | Talang queenfish | ត្រីកាឡាំង | 100.0% | - | - | - | 800.0 | 0.8% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| *Anodontostoma chacunda* | Chacunda gizzard shad | ត្រីកាម៉យ | - | - | 100.0% | - | 555.0 | 0.6% |
| *Suborder Sepiina* | Cuttlefish | មឹកស្នូក | - | 91.1% | 3.0% | 5.9% | 538.0 | 0.5% |
| | Cephalopods (squids/cuttlefish) | ពពួកមឹកស្នូកនិងមឹកបំពង់ | 62.9% | 37.1% | - | - | 510.0 | 0.5% |
| *Sardinella gibbosa* | goldstripe sardine | ត្រីគូន | 100.0% | - | - | - | 260.0 | 0.3% |
| | Crabs nei | ក្តាមផ្សេងៗ | 41.4% | - | - | 58.6% | 145.0 | 0.1% |
| | Lizardfish | ត្រីក្តចិន | 23.1% | - | 76.9% | - | 130.0 | 0.1% |
| *Siganus canaliculatus* | Whitespotted Spinefoot | ត្រីកន្តាំងក្រអូម | - | - | 100.0% | - | 126.0 | 0.1% |
| *Penaeus merguiensis* | Banana shrimp | បង្គាប៉ាវ៉ា | 100.0% | - | - | - | 120.0 | 0.1% |
| | Mollusks nei | សប្បីសត្វ ពពួកខ្យង គ្រំងាវ | 0.0% | 22.3% | 0.0% | 77.7% | 89.5 | 0.1% |
| | Mantis shrimp | បង្កងកណ្តូប | 30.2% | - | 69.8% | - | 89.4 | 0.1% |
| | Parrot fish | ត្រីសេក | 60.2% | - | 18.1% | 21.7% | 83.0 | 0.1% |
| | Shrimps nei | បង្កងប៉ាក | 24.8% | 71.1% | - | 4.1% | 72.7 | 0.1% |
| | Barracuda | ត្រីអង្រែ | 100.0% | - | - | - | 70.0 | 0.1% |
| | Rabbitfish | ត្រីកន្តាំង | - | - | 100.0% | - | 50.0 | 0.1% |
| *Eleutheronema tetradactylum* | Fourfinger threadfin | ត្រីកាវ៉ាវ | 3.2% | - | 96.8% | - | 46.5 | 0.0% |
| *Episesarma versicolor* | Violet vinegar crab | ក្តាមជើរ | 100.0% | - | - | - | 30.0 | 0.0% |
| *Crenimugil seheli* | Bluespot mullet | ត្រីក្បក | - | - | 100.0% | - | 27.0 | 0.0% |
| *Arius maculatus* | Spotted catfish | ត្រីក្អុក | 100.0% | - | - | - | 24.0 | 0.0% |
| | Rays nei | បបែល | - | 71.4% | 28.6% | - | 21.0 | 0.0% |
| *Chiloscyllium griseum* | Grey bambooshark | ឆ្លាមគីង្គក់ឬឆ្លាមឆ្កួត | - | - | - | 100.0% | 19.0 | 0.0% |
| | Congers nei | អន្ទង់សមុទ្រ | - | - | - | 100.0% | 15.0 | 0.0% |
| | Mullets | ត្រីក្បក | - | - | 100.0% | - | 14.0 | 0.0% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| *Scomberomorus commerson* | Narrowbarred Spanish mackerel | ត្រីបេកាខ្មៅ ឬត្រីបេកាឆ្នូត | 100.0% | - | - | - | 13.0 | 0.0% |
| *Brevitrygon imbricata* | Scaly whipray | បបែលមាន់ | - | 4.8% | - | 95.2% | 10.5 | 0.0% |
| *Scylla serrata* | Mud crab | ក្តាមថ្ម | 100.0% | - | - | - | 7.0 | 0.0% |
| *Epinephelus amblycephalus* | Banded grouper | ត្រីតុកកែខ្លា | - | - | - | 100.0% | 5.5 | 0.0% |
| *Scomberomorus sp.* | Spanish mackerel species nei | ត្រីបេកា | - | - | 100.0% | - | 5.0 | 0.0% |
| *Sillago sihama* | Silver sillago | ត្រីព្រលួស | - | - | 100.0% | - | 4.0 | 0.0% |
| | Flounders and soles nei | ត្រីអណ្តាតឆ្កែ | 100.0% | - | - | - | 3.0 | 0.0% |
| *Pampus argenteus* | Silver pomfret | ត្រីចាបស | - | - | - | 100.0% | 3.0 | 0.0% |
| | Pony fishes | ត្រីកិ | - | - | 100.0% | - | 2.0 | 0.0% |
| | Morray eels nei | អន្ទង់សមុទ្រ | - | - | - | 100.0% | 2.0 | 0.0% |
| *Pseudorhombus arsius* | Largetooth flounder | ត្រីអណ្តាតឆ្កែ | 100.0% | - | - | - | 2.0 | 0.0% |
| *Acanthurus sp.* | Surgeonfish | ត្រីកាតាំង | - | - | 100.0% | - | 2.0 | 0.0% |
| **សរុបរួម** | | | **24.3%** | **66.1%** | **8.5%** | **1.2%** | **99,649.0** | |